EMBASSY OF JAPAN IN CAMBODIA

# PRESS RELEASE

No. 15 PR-25/EoJ 26 February 2025

## Japan Provides US$720,304 for Improving Early Childhood Education and Promoting Regional Medical Cooperation System

The Government of Japan will provide US$720,304 in total for two recipient organizations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the recipients, to carry out the following projects:

1. 'Project for Strengthening Community-based Surgical Care System in Northeast Cambodia'
(US$245,872)
Recipient: Foundation for International Development/Relief (FIDR)

In this project, FIDR aims to improve cooperation among hospitals and health centers in northeastern Cambodia by extending the capabilities and leadership of Kratie Provincial Referral Hospital staff to serve as the regional hub for surgery. In addition, district hospitals and health centers staff will also be trained to accurately identify patients condition and to refer them appropriately to upper level hospitals.

2. 'Improve the access and quality of Early Childhood Education in the public preschools in Preah Vihear Province'
(US$474,432)
Recipient: Shanti Volunteer Association (SVA)

In this project, SVA will improve the physical and human educational environment that bridges the education gap between young children in urban areas and rural areas. In addition, SVA aims to improve access and the quality of activities in public preschools in Preah Vihear province located in northwestern Cambodia.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the

grassroots level. Since 2002, the Government of Japan has provided nearly US$60 million for over 160 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---


*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**

**ប្រចាំប្រទេសកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

លេខ. 15 PR-25/EoJ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

**ជប៉ុនផ្តល់ថវិកា ៧២០,៣០៤ ដុល្លារអាមេរិក**

**សម្រាប់ធ្វើឱ្យប្រសើរឡើងនូវសកម្មភាពអប់រំកុមារតូច និងការលើកកម្ពស់ប្រព័ន្ធ**

**កិច្ចសហប្រតិបត្តិការផ្នែកវេជ្ជសាស្ត្រក្នុងតំបន់**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៧២០,៣០៤ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណូ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយទាំងពីរ សម្រាប់អនុវត្តគម្រោងដូចតទៅ៖

<u>១. "គម្រោងពង្រឹងប្រព័ន្ធថែទាំវះកាត់តាមសហគមន៍ នៅក្នុងតំបន់ភូមិភាគឦសាន្ត នៃប្រទេសកម្ពុជា" (ថវិកាចំនួន ២៤៥,៨៧២ ដុល្លារអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ (FIDR)</u>

នៅក្នុងគម្រោងនេះ អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមមន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅភូមិភាគឦសាន្តនៃប្រទេសកម្ពុជា ដោយពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់បុគ្គលិកនៃមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ដើម្បីបម្រើជាមជ្ឈមណ្ឌលក្នុងតំបន់សម្រាប់ការវះកាត់។ លើសពីនេះ បុគ្គលិកនៃមន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពក៏នឹងទទួលការបណ្តុះបណ្តាល ដើម្បីកំណត់រោគសញ្ញាអ្នកជំងឺ និងបញ្ជូនពួកគេទៅមន្ទីរពេទ្យដែលមានកម្រិតខ្ពស់ជាងឲ្យបានត្រឹមត្រូវ។

## ២. "ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពសកម្មភាពអប់រំកុមារតូចរបស់សាលាមត្តេយ្យសិក្សារដ្ឋ នៅខេត្តព្រះវិហារ" (ថវិកាចំនួន ៤៧៤,៤៣២ ដុល្លារអាមេរិក)

## ស្ថាប័នទទួលជំនួយ៖ អង្គការសន្តិស្មគ្រចិត្ត (SVA)

នៅក្នុងគម្រោងនេះ អង្គការសន្តិស្មគ្រចិត្តនឹងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអប់រំទាំងបុគ្គល និងបរិក្ខារដែលគាំទ្រដល់ការដោះស្រាយគម្លាតការអប់រំរវាងកុមារតូចៗ នៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទ។ លើសពីនេះ អង្គការសន្តិស្មគ្រចិត្តមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន និងគុណភាពនៃសកម្មភាព នៅក្នុងសាលាមត្តេយ្យសិក្សារដ្ឋ ក្នុងខេត្តព្រះវិហារ ដែលមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៦០លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១៦០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា

ទូរសព្ទ៖៖ ០២៣-២១៧-១៦១

អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp

គេហទំព័រ៖ http://www.kh.emb-japan.go.jp

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា**
**ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**ថ្ងៃពុធ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥**

- សូមគោរព **លោក សារអេគិ ខាហ្សាតុ** នាយកអង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិប្រចាំប្រទេសកម្ពុជា
- សូមគោរព **លោកស្រី គីគុជី អាយ៉ាណុ** នាយិកាអង្គការសន្តិស្ម័គ្រចិត្តប្រចាំប្រទេសកម្ពុជា
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យា សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនចំនួន២ នាថ្ងៃនេះ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា "អ៊ិនរ៉េន" បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីគម្រោងចំនួនពីរ ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

ទី១ រដ្ឋាភិបាលលជប៉ុននឹងផ្តល់ថវិកាប្រមាណ ២៥០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ (FIDR)។

គម្រោងនេះ មានគោលបំណងផ្តល់ការព្យាបាលវះកាត់សមស្របដល់ប្រជាពលរដ្ឋដែលមានមូលដ្ឋានក្នុងខេត្តក្រចេះ គម្រោងនេះនឹងពង្រឹងចំណេះដឹង និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងមន្ទីរពេទ្យក្នុងខេត្តក្រចេះ និងស្ថាប័នវេជ្ជសាស្ត្រក្បែរនោះ ដោយធ្វើការណែនាំឧបករណ៍វះកាត់ថ្មី និងពង្រឹងសមត្ថភាពព្យាបាល និងដឹកនាំរបស់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា។តាមរយៈសកម្មភាពទាំងនេះ ខ្ញុំរំពឹងថាកិច្ចសហប្រតិបត្តិការផ្នែកវេជ្ជសាស្ត្រនៅតំបន់ភាគឦសាននៃប្រទេសកម្ពុជា ដែល

ផ្តោតលើការវះកាត់ នឹងត្រូវបានបង្កើតឡើងក្នុងខេត្តក្រចេះជាគោល ហើយប្រជាពលរដ្ឋនឹងអាចទៅពិនិត្យយ៉ាងសកម្មនៅមន្ទីរពេទ្យ និងទទួលបានការព្យាបាលវះកាត់សមស្របដោយមិនបង្អង់យូរ។

ទី២ រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាប្រមាណ ៤៧០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)។

ក្នុងគម្រោងនេះ សកម្មភាពចំនួនបីនឹងត្រូវបានអនុវត្ត៖ (១) ការកែលម្អអគារមតេយ្យសិក្សា និងសួនកុមារ (២) ការអភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សា និងមន្ត្រីរដ្ឋបាលអប់រំ។ល។ និង (៣) ការលើកកម្ពស់ការយល់ដឹងរបស់មាតាបិតា ចំពោះការអប់រំកុមារតូច នៅក្នុងសាលាមត្តេយ្យរដ្ឋ ក្នុងខេត្តព្រះវិហារ ដែលមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ តាមរយៈសកម្មភាពទាំងនេះ នឹងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការអប់រំ និងគុណភាពនៃសកម្មភាពអប់រំ ដោយការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអប់រំ។ លើសពីនេះ វាក៏នឹងរួមចំណែកក្នុងការផ្សព្វផ្សាយលទ្ធភាពទទួលបានការអប់រំផ្នែកមត្តេយ្យសិក្សាដែលមានគុណភាពខ្ពស់ និងស្មើភាពគ្នា ដូចដែលមានចែងក្នុង "ផែនការយុទ្ធសាស្ត្រអប់រំ ២០២៤-២០២៨"។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន ដែលរួមមានមិនត្រឹមតែក្នុងវិស័យសុខាភិបាលនិងអប់រំប៉ុណ្ណោះទេ ថែមទាំងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍សង្គម រួមទាំងបរិស្ថានផងដែរ។ រដ្ឋាភិបាលជប៉ុន នឹងចូលរួមចំណែកដោះស្រាយបញ្ហានានា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិរបស់ជប៉ុន។

ជាទីបញ្ចប់នៃការថ្លែងសន្ទរកថារបស់ខ្ញុំ ខ្ញុំសូមឱ្យគម្រោងទាំង២ ដែលចុះហត្ថលេខានាថ្ងៃនេះ ដំណើរការទៅដោយរលូន និងទទួលបានភាពជោគជ័យនាពេលអនាគត។ ហើយខ្ញុំសូមជូនពរលោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។ សូមអរគុណច្រើន។